បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

# សេកសោមបណ្ឌិត

# ពាក្យកាព្យរបស់ថី គិម-ហាក់

លេខានុការ នៅស្ថានប្រៃសណីយ៍ក្រុងកម្ពុជា

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈបានយល់ព្រម

បោះពុម្ពលើកទី ៣

INSTITUT BOUDDHIQUE

NA - 73

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រួង ចាន់ណា** ម្ចាស់គេហទំព័រ៥០០០ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្មៅ ឃុនសំរ៉ង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥០០០ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

សេកសោមបណ្ឌិត

# ពាក្យកាព្យរបស់ថី គិម-ហាក់

លេខានុការ នៅស្ថានប្រៃសណីយ៍ក្រុងកម្ពុជា

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈបានយល់ព្រម

បោះពុម្ពលើកទី ៣

LIBRARY
BUDDHIST INSTITUTE
៣៦៣០/៥៨

[illegible]
ភ្នំពេញ
[illegible]

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

[illegible] ព.ស. ២៥០៨ [illegible]
[illegible]
[illegible]

1-73

www.budinst.gov.kh www.elibraryofcambodia.org

# LE PERROQUET DOUÉ DE SAGESSE

POÈMES COMPOSÉS PAR

KIM-HAK

SECRÉTAIRE DES POSTES ET TÉLÉGRAPHES

AU CAMBODGE

CETTE PUBLICATION A REÇU L'APPROBATION
DU CONSEIL DES MINISTRES ET DES CHEFS DES DEUX SECTES

Troisième Edition

PHNOM-PENH
EDITIONS DE L'INSTITUT BOUDDHIQUE
1965

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org


www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

អហើរខ្ញុំ ថ្វាត់ថ្វាយបង្គំ ប្រណម្យហត្ថា ម្រាមដៃផប់ដាក់ ដោម ដាក់សិរសា ដល់ព្រះសាស្តា សម្មាសម្ពុទ្ធ ។ ព្រះអង្គបានត្រាស់ ញេយ្យធម៌ច្បាស់ ល្អល្អះបំហុត ពិសេសពិសាល ត្រកាលផ្តើម ម្តុដ ព្រះទ័យល្អសុទ្ធ ផុតគ្មានអ្វីស្មើ ។ មេត្តាសព្វសត្វ ករុណា គ្មានបាត់ ខ្ជាត់ខ្ជាត់សើរើ ទ្រង់ប្រោសប្រដៅ ដោយនូវដំណើរ កិរិយាប្រសើរ ដើរកាន់សុខា ។ ព្រះអង្គធ្វើយាន នាំសត្វហោះ ធ្យាន កាន់ស្ថានអមតា នគរកែវឯក បំបែកណាស់ណា និរទុក្ខា មហាក្សេមសល់ ។ រីកិរិយា នមស្សការា ខ្ញុំចូរមានដល់ ព្រះ សទ្ធម្មល្អលន់ គុណធ្ងន់ពេកសល់ ធ្វើសត្វឲ្យយល់ និព្វានឆាយ ឆៃ ។ ព្រះធម៌រំលត់ ភ្លើងកិលេសសុទ្ធ ព្រមភាំងទុក្ខភ័យ ឧប- ទ្រពទាំងពួង សឹងឲ្យបរាជ័យ ជាលបាញ់តេជងៃ ធម៌ថ្លៃសម្ភារៈ។ មិនតែប៉ុណ្ណោះ ហត្ថាខ្ញុំផ្ដោះ ក្រាបក្រោមបាទា ព្រះអរិយសង្ឃ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

រាល់អង្គនានា ពីព្រោះលោកជា ទក្ខិណេយ្យបុគ្គល ។ រាគាទិ-
កិលេស សឹងផុតរបេះ ឥតសេសគ្មានសល់ អាសវធម៌ មិនមាន
ជាបជល់ លោកធ្វើឲ្យផុត បំរើនច្រើនបាន ។ រួចស្រេចកាលណា
ខ្ញុំសូមបរបា អតីតាជាន ដើមចិត្តបំណង ប៉ុនប៉ងក្នុងប្រាណ ខ្លួន
ខ្ញុំប៉ុន្មាន ដោយសច្ចំពិត ។ មាឃពេញបូណ៌មី ចន្ទ្រចែងរស្មី
តារាចោមជិត ចោមជាបរិវារ ព្រះចន្ទ្រាឫទ្ធិ នៅឯបនែបនិត ជិត
អចិន្ត្រៃយ ។ រាត្រីស្ងាត់សល់ ឮសូរតែខ្យល់ លលកជលស័យ
ក្បែរឆ្នេរសាគរ ឮខ្ទរខ្ទារព្រៃ វាយោផាត់វៃ បែកបាក់រុក្ខា ។ ធ្លាក់
ដល់ធរណី ឈើបែកខ្ទេចខ្ទី លើផែនសិលា ថ្មជាធំ ៗ ជើងភ្នំ
បព្វតា ស្រុកការមសីមា ព្រឹក្សាពេញពាស ។ វិម្រឹគបក្សី ផ្អើល
ក្នុងរាត្រី ពន្លឺចែងច្បាស់ ខ្លះយំខ្លះស្រែក សំរែកឮណាស់ ដោយ
ខ្យល់បោកប៉ះ ទ្រនំគ្រឹហា ។ មនុស្សក្នុងភូមិភាព វេលាពេល
យប់ ឈប់ធ្វើការងារ សំរាកសំរាន្ត កំសាន្តទយា កើតមាន
ភ័យា ដោយយល់ភេទប្លែក ។ ចិត្តស្លុតតក្កមា គិតពិចារណា
ដល់ក្តីប្រាសបែក និរាសបែកស្ថាន សន្តានអនេក មកនៅឯងឯក
លើឆ្នេរសាគរា ។ រីអាត្មាខ្ញុំ សែនព្រួយស្មើរយំ កណ្តាលអធ្រា នឹក
ដល់អកុសល មកប្តល់ក្នុងគ្រា នេះខានបូជា មាឃពេញបូណ៌មី ។
នឹកស្តាយអស់កល ស្មើរនឹងដាច់ខ្យល់ កណ្តាលរាត្រី ទឹកនេត្រ

www.budinst.gov.kh www.elibraryofcambodia.org

ហៀរស្លេង គ្មានក្រែងបេញខ្ចី គិតព្រះជិនស្រី ធិបតីលោកា ។ ឱះឱខ្លួនខ្ញុំ មានកងកម្មធំ បាកបោលញាតិសា លោហិតមិត្រផង មករងទុក្ខា បៀតដើងបព្វតា ព្រឹក្សាក្រាស់លន់ ។ នៅឆ្ងាយពីសង្ឃ បើមានចំណង់ ចង់គិតដល់គុណ ព្រះរតនត្រ័យ ពីបាកពេកលន់ មួយទៀតមហាជន ស្រុករាមឯងណា ។ មិនបេះស្គាល់ធម៌ នាំគ្នាឈ្លូជរ ធ្វើតែបាណា សម្លាប់ជាប់ត្រី ជាស្បៀងអាហារ ចិញ្ចឹមជីវ៉ា ការបុណ្យគ្មានគិត ។ ព្រះសង្ឃក្នុងឃុំ ថេរាតូចធំ ច្រើនគ្មានគំនិត ខាងធម៌វិន័យ ល្ងង់ខ្លៅពេកពិត ខ្ញុំយកធ្វើមិត្រ ជិតស្មើរពុំបាន ។ មានកាលមួយថ្ងៃ មានសង្ឃប្រពៃ មួយអង្គដាក់ឋាន អ្នកស្រុកគេថា លោកនេះបំណាន ចំណេះប៉ុន្មាន លោកបានសិក្សា ។ លោកនិមន្តមក ស្វែងស្វះរាវរក រូបឈ្មោះខ្ញុំណា ខ្ញុំក្រាយបង្គំ ប្រណម្យសួរថា បពិត្រមហា ថេរាអម្ចាស់ ។ វត្តព្រះករុណា តើមានជនា ទាំងក្មេងទាំងចាស់ ធ្វើខបោសថ ច្រើនឬតិចណាស់ សូមករុណាម្ចាស់ ត្រាស់ប្រាប់ខ្ញុំភ៉ា ។ ខបោសថអ្វី សូមទោសលោកថី ប្រាប់ឲ្យអាត្មា បានម្តងទៀតស្តាប់ តាមសព្ទភាសា ខ្មែរយើងវិញភ៉ា អាត្មាយល់ផង ។ ខ្ញុំក្រានោះឯង ចិត្តសឹងបម្លែង ស្លាក់ស្លែងកន្ទង ទើបទូលទៀតថា ជាការពីរជង តាមដោយទំនង ជងដើមសេចក្តី ។ ក្នុងវត្តព្រះគុណ តើមាន

www.budinst.gov.kh www.elibraryofcambodia.org

ពួកដន ក្មេងចាស់ប្រុសស្រី ឱតឪរក្សា សីលាប្រាំបី មានវេរឬអីមេត្រីប្រាប់ផង ។ លោកគ្រូថាវ៉ើយ អាត្មាយល់ហើយ ពាក្យជីស្លួរសង ញោមញាតិអាត្មា ពុំសួរគឺកកង ពីរនាក់ដាក់ហោង ធ្វើសីលប្រាំបី ។ ឱលោកបីអើយ មនុស្សយើងច្រើនស្បើយ ពុំគិតសេចក្ដីបាបកម្មវេរា ពាំនៀរលោកីយ ចិត្តច្រើនតិរិយ ក្ដីបាបក្រៃណាស់ ។ ខ្ញុំបានស្ដាប់ស្រេច ទើបខ្ញុំប្រែគេច សើចឮហះៗ ថាឱពុទ្ធោព្រះករុណាម្ចាស់ កាន់សីលតិចណាស់ តាមសាសន៍ព្រះពុទ្ធ ។ មនុស្សពេញទាំងស្រុក គ្មានគិតរកសុខ ពុំមានវន្ទត់ ខ្លាចបាបអប្រិយ ចិត្តពុំបរិសុទ្ធ ឲ្យបានខ្លួនផុត ពីវដ្ដសង្សារ ។ នៃព្រះគុណម្ចាស់ គួរគិតឃើញណាស់ ដំរះធម៌អាថ៌ រៀនពាក្យបាឡី សំដីវោហារ មើលអស់គំរា សព្វសាស្ត្រនានា ។ ហើយព្រះតេជព្រះគុណ ចូរខំអត់ធន់ ប្រាប់ញាតិរាល់គ្នា ទេសនាឲ្យស្ដាប់ បង្ក្រាបវេរាឲ្យមានសទ្ធា ភ្លឺថ្លាក្នុងចិត្ត ។ ភិក្ខុសាមណេរ ត្រូវខំប្រឹងតែ រៀនរឿងភាសិត សាស្ត្រាបាលី សំដីក្រមក្រិត្យ ទើបបានប្រព្រឹត្ត ពិតតាមពុទ្ធា ។ ឱលោកបីអើយ អាត្មាចាស់ហើយ មានរោគជរា ជំងឺជំកាត់ ស្កាត់រាល់វេលា ក្របើពណ៌នា ដំរាបប្រាប់ណា ។ អាត្មាអរណាស់ បានឮប្រសាសន៍ ដាស់តឿនអាត្មា តែអស់ញាតិញោមពុំព្រមតាមរ៉ា គេគិតឃើញថា ពិបាកសល់ខ្នាត ។ ក្នុងវត្តអាត្មា

www.budinst.gov.kh www.elibraryofcambodia.org

មានតែគំរា ខ្ជី ៗ ខ្ជូបខាត ភិក្ខុសាមណេរ ប្រឹងតែសង្វាត រៀន
ពុំឲ្យឃ្លាត ព្រាត់មួយវេលា ។ គំរាអស់នោះ មានធម៌ដោះគ្រោះ
អាគមរោគា សម្លាប់ចង្រៃ ចង្រ្កនានា បើសូត្រកាលណា ឡើង
សិរីជោគ ។ ធម៌សូត្រក្លូវទឹក ធម៌វែងសង្ខឹក សន្ធាប់ព្រាយព្រោក
សូត្រស្មើរក្រឡាប់ អ្នកស្តាប់ស្មើរងោក ដែលសំពះលោក ភ្នែកឈ្ងោក
មមី ។ អាត្មាសព្វថ្ងៃ បេះធម៌មួយនៃ កែភ័យព្យាធិ តែមុននឹង
សូត្រ ត្រូវរៀបផ្កាភ្ញី រៀបរានពិធី បាយសីពែផង ។ ទេសឯកដប់
ហត្ថ ពៃបីសង្កាត់ ឲ្យល្អហ្មត់ហ្មង ប្រាក់មួយណែនដាក់ តំកល់
ដាក់បង ព្រៃមួយក្រៃផង ប្រគេនអាត្មា ។ ឋិនៅស្រុកគេ ស្រុក
ចាញ់ឥតថ្លៃ ច្រើនតែខ្លោចផ្សា គួរឋិសូត្រមន្ត កុំទុរជនណា ទើប
កើតសុខា លាភាល្អប្លែក ។ បពិត្រករុណា លោកមានមេត្តា ខ្ញុំ
មាំមួនឯក តែជាខ្លួនខ្ញុំ ពិតពុំប្រកែក ឲ្យឃើញដោយឡែក ប៉ែក
ខាងពុទ្ធា ។ ខ្ញុំករុណាម្ចាស់ មនោអរណាស់ នឹងអង្គទ័យា មេត្តា
ដល់ខ្ញុំ សុខុមនាំពា ឲ្យកើតជោគជា ភិយ្យោភាពតទៅ ។ រីខ្ញុំ
ករុណា ជាប់ធ្វើរាជការ គេច្រើនឃោរឃៅ ការច្រើនពេកពន់ ស្មើរ
ធន់ពុំនៅ ឲ្យជាប់យូរទៅ នាស្រុកនេះណា ។ របៀបពិធី ច្រើន
ជាន់ច្រើនទី ពិបាកណាសា រៀបពុំកើតទេ សូមគ្នេរមេត្តា ចាំដល់

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃណា រយោលការគេ ។ លោកគ្រូបានស្តាប់ ជាអាត្មាភាព មើលព្រះសុរិយេ ដិតអស្តង្គត ផុតដើងមេឃេ អាត្មាសូមលេ ណាទៅវត្តហើយ ។ កន្ត្រាក់ចង់យាម ស្ទុះដើរចេញភ្លាម ស្ទាត់ ស្ទៀមកន្តើយ ឯខាងខ្លួនខ្ញុំ ទុក្ខគំពុំស្បើយ គិតព្រះត្រាណត្រើយ សក្យមុនី ។ ឱព្រះសាសនា តើដល់កាលណា ល្អក្នុងដែនទី នគរកម្ពុជា មហាធរណី ឲ្យបានជាទី គួរគប្បីស្រួល ។ ព្រះសង្ឃ ច្រើនអង្គ ចិត្តពុំស្មោះត្រង់ ចង់ជួយតម្រួល តម្រូវសាសនា ឲ្យបាន ស្រួលបួល គិតតែព្រាល់ច្រួល រកលាភបូជា ។ តែធម៌វិន័យ ពិតពុំរវៃ រៀនភាវនា ទេសនាប្រាប់សត្វ កំចាត់រាគា គិតតែ លាភា ពុំភ្ញាក់ប្រាណ ។ ខ្ញុំរឹងគិតខ្វល់ គិតហើយតប់ប្រមល់ ក្នុងមណ្ឌលស្ថាន ប្រឹងចាប់ក្រដាស់ គួរវាសកំសាន្ត គិតធ្វើឲ្យបាន រឿងសេកនេះណា ។ ធ្វើជាពាក្យឃ្លោង ពុំបានប្រាជ្ញប្រោង ឈោងតាមវោហារ ប្រាជ្ញាក៏ខ្លី ស្មារតីតិចណា សូមព្រឹទ្ធាចារ្យ ករុណាអត់ទោស ។ បើមិនគួរគាប់ ពាក់ពានលើច្បាប់ ពោល ទៅលឿនជ្រួស សូមលោកមេត្តា ខមចសន្តោស មេត្តាប្រាណ ប្រោស ប្រណីទោសា ។ រឿងសេកនេះឯង ពុំបានជាវែង ថ្លែង តាមប្រាជ្ញា ទុកជូនជនផង សោះសៅហ្មងសា មើលលេងកំឡា

www.budinst.gov.kh www.elibraryofcambodia.org

បង្ការអប្រិយ ។ ដល់ពោធិសត្វ លោកត្រាច់ចុះថ្វាត់ ត្រាស់ក្នុង លោកីយ បាននាមថ្លៃថ្លា សិរិអារ្យមេត្រី[១] សូមបុញ្ញរាសី មេត្រីខ្ញុំ ដាក់ ។ ឲ្យខ្ញុំបានទាន់ កើតពេលដំណាន់ ព្រះពុទ្ធសមស័ក្តិ ឲ្យ បានស្តាប់ធម៌ ទេសនាអន័ត្ឋ អនេកកុំអាក់ ខានធ្លាក់មួយថ្ងៃ ។ ដល់អស់សង្ខារ សូមកុសលា ជូនខ្ញុំឆាប់វៃ ឲ្យដល់និព្វាន សុខ សាន្តប្រពៃ ឧបទ្រពចង្រៃ កុំបីបៀតបាន ។ អស់ជនប្រុសស្រី បានមើលសេចក្តី រឿងនេះប៉ុន្មាន សូមកបតេជះ ឈ្នះមារគ្រប់ស្ថាន ឲ្យបានសម្រាន្ត ឋាននិព្វានអើយ ។

១ បាលីថា សិរីអរិយមេត្តេយ្យ, សំស្រ្កឹតថា ស្រីអារ្យមៃត្រេយ ។

www.budinst.gov.kh www.elibraryofcambodia.org

កាលនោះមែនមាន សង្ឃមួយប្រជាន ធំយសមុះហិមា ជាតិជាព្រះសង្ឃ ទ្រទ្រង់សិក្ខា ត្រួតសង្ឃនានា និគមមួយនៃ ។ លោកចីញ្ចឹមសត្វ សេកសោមល្អក្កាត់ បក្សប្រពៃ កបកើតប្រាជ្ញា ឆ្លាសវាសវាងវៃ កិច្ចកលទីទៃ សេកសោមចាំបាន ។ លោកមហាថេរ មានចិត្តមេត្តា អាសូរតិរច្ឆាន រក្សាស្ងួនគ្រង ទុកនៅក្នុងស្ថាន ចំណីប៉ុន្មាន បានសេកភោក្តា ។ ក្នុងអារាមនោះ កើតមានជម្លោះ ប្រកែកបដិបា៉(១) ពួកឧបាសក ភិក្ខុសិកា ពួកសាមណេរា ជជែកឆោឡោ ។ អំពីធម៌ផង ទ្រហឹងអឺងកង រំពងបះបោរ ខ្លះប្រឹងជំទៀង ខ្លះប្រឹងបន្ទោ ខ្លះលាត់ដើងខោ បោលអាវឆ្វាយខ្លួន ។ កើតជារឿងប្តូល់ កើតចលាចល ក្រហល់មាំមួន ខ្លះប្រឹងគំនុំ ទឹងងំគុំគួន ព្យាបាទធំធួន ដល់ក្បួនច្បាប់ណា ។ សេកសោមសត្វថ្លៃ គាប់ជួនមួយថ្ងៃ ល្អិតល្អៃចិន្តា បិត្តំភាំងគិតដល់រូបអាត្មា មករងទុក្ខា លំបាកច្រើនលន់ ។ បក្សាសោយសោកយំយែកអាមោក្ខ ដោកដោរទុរន់ ទុរាគោកយាក វិបាកស្រពន់

១ ក្លាយពីពាក្យថា បដិបក្ខ ( ពួកប្រឆាំង ) ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

ស្ទើរក្ស័យពុំធន់ ធ្ងន់ក្នុងឱរា ។ ដល់រាត្រីស្ងាត់ ទើបបក្សាសត្វ ព្រោកប្រាជ្ញរោហារ ឈោងចឹកចំណាង ដែលចងអាត្មា ដាច់ស្រេចកាលណា បក្សាហើរភ្លាត់ ។ ដល់មកក្រៅកុដិ ដ៏វិសេសសុទ្ធ ហើយបក្សាសត្វ ហើរប្រទក្សិណ វត្តបីជុំថ្វាត់ រួចស្រេចហើរស្កាត់ កាត់ចូលព្រៃព្រឹក្ស ។ បក្សាវិយោគ ចិន្តាស្តាយលោក មេវត្តសន្ធឹក ហើរផងយំផង មមៃរឹងនឹក អាណោចពន្លឹក ទឹកពេញនេត្រា ។ ស្រែកថ្លែងទំនួញ ពិលាបតែងថ្ងូញ ឋាឱលោកតា ខ្ញុំលាសិនហើយ គង់ឲ្យសុខា ខ្ញុំព្រះករុណា ទ្រាំនៅពុំបាន ។ លោកតាមានគុណ គុណតាប់មហាធ្ងន់ ធ្ងន់ឥតប្រមាណ ចំ-ណាប់កម្រ ក្រអ៊ីប្រៀបបាន ធំជាងសូរ្យឆាន ល្អជាងសុវណ្ណ ។ ធ្វើម្តេចតាអើយ ទ្រូងខ្ញុំសែននឿយ រឿយៗ ដាក់ស្បាន់ ឃើញពុទ្ធបរិសុទ្ធ ច្រើនពួកប្រកាន់ ប្រកែកតាប់តាន់ ពីព្រះធម្មា ។ ខ្ញុំជាបក្សា ក្នុងទ្រូងខ្លោចផ្សា អួលអាក់ទ័យា ឮគេប្រកែក ជជែកឈ្លោះគ្នា ពីព្រះធម្មា មិនគួរច្នេះឡើយ ។ ព្រះធម៌មហាថ្លៃ ត្រជាក់វិស័យ ជាងទឹកត្រាណត្រើយ ម្តេចប្រែជាក្តៅ លើសភ្លើងវិញហើយ ឱទេវតាអើយ ជួយខ្ញុំគ្រាហ្មឹង ។ សូមបង្ហាញផ្លូវ មាគ៌ាតម្រូវ តម្រួយទីពឹង នឹងលោកអ្នកប្រាជ្ញ អាចជាខុននឹង ឲ្យបានរឹងប៉ឹង ដឹងច្បាប់ទាំងឡាយ ។ យំហើយបក្សា ហើរលើវេហា

www.budinst.gov.kh www.elibraryofcambodia.org

អាកាសវែងឆ្ងាយ តាមដោយពន្លឺ ព្រះចន្ទ្របែងសាយ ចិត្តពុំ
សប្បាយ ណាយស្រាលឡើយណា ។ ហើរកាត់វាលព្រៃ គិរីទីទៃ
ច្រកជ្រោះបព្វតា សមុទ្រសាគរ ខ្វារខ្វះវត្តា សោកគិតអនិច្ចា បិន្ទា
សង្វេគ ។ ឱមើលតិរច្ឆាន ដេកត្រៀបដាសដាន ដោយពួកដោយ
ប៉ែក ដូចពួកតាអញ បែកទៅជាផ្នែក ចិត្តរឹងដាងដែក ប្រកែក
គ្នាវរ ។ មើល ៗ សត្វខ្លា រូបរាងសង្ហា ប្រឹងស្រែកញខ្វរ ប្រកួតនឹង
ជ្រូក ព្រៃធំគឃរ ទាំគាស់រឹកវរ រំពងអស់ព្រៃ ។ អើះអើនេះដូច
ឧបាសកខ្វូច ឈ្មោះគ្នានិរភ័យ និរភិតអំពី ធម៌និងវិន័យ នាំឲ្យបរា-
ជ័យ ចោកទាបសាសនា ។ ឱមើលក្របី ដេកត្រាំក្នុងដី ល្បាប់
ជ្រោណសា ប្រឹងក្រោកឡើងដើរ ដំណើរយាត្រា រករាជសីហា
ឥស្សរាសត្វផង ។ ដល់ហើយទម្លាក់ សិរសាឱនដាក់ ធ្លាក់ក្រោម
កន្លង គិតចង់ប្រកួត អំនួតទ្រើសឃ្លង រាជសីហទង្វង់ ពិតពុំអើពើ ។
អើនេះដូចជា ពួកមនុស្សរាល់គ្នា ល្ងង់ខ្លៅភ្លីភ្លើ បានយល់បណ្ឌិត
ហើយធ្វើងីងើ ចង់នៅពីលើ បណ្ឌិតវិញណា ។ អួតកំឡាំងខ្លៅ
ខ្លាចអសោចខ្មៅ អាប់ឥតប្រាជ្ញា មិនឲ្យបណ្ឌិត នៃបនិតអាត្មា
កើតមានឥជ្ជា ឈ្មានីសប្រាជ្ញប្រាយ ។ ន៍មើលដំរី ស្តេកស្តម្ភពីសី
ភ្លុកវែងត្រសាយ ត្រសុះសក្តាត់ ដេកសម្រាកកាយ ពួកស្តេទាំង
ឡាយ ដេកហ៊ុំជុំជិត ។ នេះបំជាត្រូវ ត្រង់តាមគម្រូវ ដូចជនបេះគិត

www.budinst.gov.kh www.elibraryofcambodia.org

បានឃើញអ្នកប្រាជ្ញ មកមីរងនឹត សាកសួរក្រុមក្រិត្យ ពិនិត្យធម៌អាថ៌។ សោកសត្វបវរ ប្រឹងគ្រាច់គោចរ តាមអាកាសា នៅព្រៃទាំងសង ផ្អៀងផ្អឹងផ្ទេជ្ជា មើលដើមរុក្ខា ព្រៀបព្រៃពេញពាស ។ មើលយូរ យង់យល់ ដើមចន្ទន៍សកល ធំខ្ពស់ឱភាស ឱភាយល្អប្លែក ក្រ ឃើញដូចមាស មិនមានពោរពាស ហើយសោកគិតថា ។ ឱដើម បន្ទន់បៃង ខ្ញុំមក្រអូបស្តែង ល្វេងល្ហើយណាសា មនុស្សកម្រជាន មកស្ពានអាត្មា ដុះដោយព្រឹក្សា ឆ្ងាយជ្រៅមុះហិមា ។ ដូចជាអ្នក ប្រាជ្ញ បរិបូណ៌អំណាច ស្វាចគីរីដ្ឋា កម្រកើតនៅ ស្រុកធំនានា តែងកើតភាភ និគមកៀនកោះ ។ បក្សាហើរហិច កាត់ភ្នំភិលសេច ខ្សៀយព្រួយកាយអស់ កំឡាំងពោរសេស់ រសេះរសោះ ស្មើរតែនឹង ពោះ ខ្លួនស្លាប់ដោយដី ។ ហើរហើយគិតផង រាយស្លាបកន្ទង លុះទៀបរាត្រី ផុតស្ទាងកាលណា បក្សាពីសី បន្ទាបខ្លួនខ្មី ចូល ផ្ទៃរសាគរ ។ ផឹកទឹកសមុទ្រ ប្រែខារខាប់មុត រន្ធត់ពោះព សត្វ សោកគិតថា ឱខ្លួនអញវរ ម្តងនេះនឹងមរ- ណាស្លាប់ដឹងឬ ។ ខាន ជួបអ្នកបេះ អ្នកមានចំណេះ ខានបានដឹងឮ ស្តាប់ធម៌ទេសនា ជា ទីបំភ្លឺ ចូលផ្លូវគាប់គឺ និព្វាននាយឯង ។ ឱះឱខ្លួនអញ នឹកហើយ សែនក្តាញ់ សែនក្តាន់ចម្លែង មកស្លាប់ដោយព្រៃ គ្មានទីកន្លែង

www.buddhist.gov.kh / www.elibrary.cambodia

បពិត្រទេវតា ដែលស្ថិតនិតនៅ ជ្រោះជ្រៅផលសា សូមជួយសង្គារ
ខ្ញុំកុំឲ្យក្ស័យ ។ ជួយទុកជីវិត ឲ្យបានស្ថេរស្ថិត យូរជាប់អាល័យ ខ្ញុំ
នឹងរិតរំ រៀនធម៌មហាថ្លៃ ឲ្យបានជាមហៃ មហាបេះជ្រៅជ្រះ ។
ខ្ញុំជួយសាសនា ព្រះមុនីសាស្តា ដែលទ្រង់បានត្រាស់ សំដែងថ្លែង
ទុក ឲ្យអស់ជាតិសាសន៍ សូត្ររៀនឲ្យច្បាស់ ជាស់តឿនបិត្តា ។
កាលនោះមែនមាន ទេវតាប្រធាន មួយធំណាសា បានស្តាប់សំដី
បក្សីបរបា ទើបចិត្តជ្រះថ្លា អាសូរសេកសត្វ ។ និម្មិតក្លែងខ្លួន ជា
ចាស់សមសួន រូបស្រេចហើយថ្វាត់ យកគង្គាថ្លា ពីសាឈ្មុយក្តាត់
ដាក់ក្នុងស្នូកសត្វ ខ្យងស័ង្ខសោភ័ណ ។ ហើយដើរយាត្រា ចូល
ជិតបក្សា សេករិះគិតគ្នាន់ ថានេះគឺជា ទេវតាសោភ័ណ ដំណើរ
រូសរាន់ ល្អដូចរាជសីហ៍ ។ ទេវតាព្រាហ្មណ៍ព្រឹទ្ធ លុះចូលដល់
ជិត ជិតកាយសេកខ្វី យកខ្យងស័ង្ខសុទ្ធ ឲ្យសេកពីសី ហើយ
ពោលសំដី ទៅកាន់សេកថា ។ សេកអើយសេកសត្វ ចូរចៅ
កំបាត់ ទុក្ខះហើយភោក្តា ទឹកស្រស់ល្អសល់ កុំខ្វល់ចិត្តា ជានា
នៅតា រក្សាព្យាបាល ។ សេកបានស្តាប់ហើយ ពិតពុំលង់ឡើយ
ត្រេកអរត្រអាល ផឹកក្រេបគង្គា ពិសេសពិសាល រូបស្រេចដំណកល
សាកសួរព្រឹទ្ធា ។ បពិត្រលោកតា លោកជាទេវតា ទ្រង់ទ្រធម្មា
ឬមួយជាយក្ស គន្ធព្វនាគា ប្លែងកាយមារយា ឲ្យខ្ញុំភិតភ័យ ។

www.budinst.gov.kh www.elibraryofcambodia.org

កាលនោះទេវតា ស្តាប់ជាក់កាលណា ក្រទ្យាខ្លួនវៃ ជាទេវតាសុទ្ធ ចំហុតប្រពៃ ទើបថ្លែងសំដី ស្តីនឹងបក្សា ។ នែចៅសេកសោម ជំមានរូបឆោម ល្មមគួរស្នេហា យើងនេះមិនយក្ស អារក្ខអ្នកតា យើងជាទេវតា រក្សាសមុទ្រ ។ សេកសោមស្តាប់ហើយ ត្រាន់បានធូរស្បើយ ឱនកាយលំអុត ក្រាបក្រោមបាទា ទេវាបរិសុទ្ធ ពិតពុំតក់ស្លុត ចងជាប្រស្នា ។ អហំរីខ្ញុំ សូមក្រាយបង្គំ បរមទេវា ខ្ញុំកើតវិមតិ សង្ស័យណាសា ហេតុម្តេចដលេសា នាសាគរា ។ ទឹកប្រែភ្នាវពេក គួរកើតវិវេក ដឹកទៅវេទនា ពុំសាបដូចទឹក ទន្លេគង្គា បឹងបួនានា ស្រះអូរទីទៃ ។ សូមលោកមេត្តា ប្រាប់ខ្ញុំក-រុណា ឲ្យអស់កលន័យ តាមដោយគន្លង ទំនងញាណញៀយ្យ ដោយលោកភាងវៃ ឆ្លៀវឆ្លាតវិជ្ជា ។ ទេវតាស្តាប់ហើយ ទើបតាំងឆ្លាស់ឆ្លើយ នែចៅសោភា ទឹកមហាសមុទ្រ ប្រែមុតក្លៀវក្លា មកពីត្រាំគ្នា យូរយារពេកក្រៃ ។ ត្រាំនៅផ្អាប់ផ្អូរ យូរកាលមិម្លួរ កើតអំបិលប្រែ មិនដូចជាទឹក ទន្លេឡើយនៃ សាបល្អឆ្ងាញ់ក្រៃ ទេណាចៅណា ។ នៅឯទន្លេ ជលភ្លៀងច្រើនមេ ទឹកហូរយាត្រាធ្លាក់មកសមុទ្រ ពុំផ្អាប់ផ្អូរណា ទើបបានពិសា សាបសមមនុស្សផង ។ សេកបានស្តាប់ជាក់ ដូចជាកន្ត្រាក់ ភ្ញាក់ខ្លួនកន្លង សែនត្រេកសាទរ អំណរចម្បង ទើបថាពិតហោង ទេវតាមហាថ្លៃ ។

www.budinst.gov.kh www.elibraryofcambodia.org

បពិត្រទេវតា សូមលោកករុណា ដ្បិតខ្ញុំសង្ស័យ នឹងមនុស្សច្រើន គ្នា វេទនាផ្លូងថៃ ដដែកភល់ថ្ងៃ ពីរឿងបូជា ។ ដល់ពួកទេវតា គ្រុឌភាជបក្សា អារក្ខនានា និងពួកទេវតា នៅដោយអគ្វា កើត ទាស់ទែងគ្នា សព្វថ្ងៃនេះណា ។ អ្នកខ្លះចូលចិត្ត ប្រតិបត្តិខាប ឫទ្ធិ ពពួកទេវតា តុបតែងបុណ្យផង សង់រោងគ្រៀបគ្រា ទៀន ធូបម្ហូបម្ហា បូជាច្រើនសល់ ។ អ្នកខ្លះធ្វើបុណ្យ គ្រប់កាលច្រើន លន់ ពិតពុំខ្វាយខ្វល់ ធ្វើភនព្វការ ទេវតាដោយកល់ កំចូបាន ពីភាល់ យល់ក្នុងចិត្តា ។ ប៉ុន្តែធ្វើបុណ្យ រួចហើយផ្សាយគុណ ឧទ្ទិសផលា ជូនដល់ជំនុំ ក្រុមពួកទេវតា ឲ្យបានសុខា រក្សាបុរី ។ សាសនាប្រសើរ កំពូលលុបលើ ធំលើសអ្វី ៗ បើធ្វើបែបនេះ ត្រូវខុសឬអី សូមលោកប្រណី ប្រាប់ខ្ញុំតិចភី ។ ស្តាប់ប្រស្នា សេក ទេវាសែនត្រេក ឆ្លើយតបបក្សា នៃចៅសេកសោម ឆោម កបប្រាជ្ញា ចូរផ្ចង់សោតា ស្តាប់ឲ្យជាក់ស្បាន់ ។ បុគ្គលឯណា បូជា ទេវតា ដោយនូវអីវ៉ាន់ គ្រឿងអាមិសទាន រាប់លានសែនថ្វាន់ ពុំស្មើអ្នកកាន់ យកធម៌បូជា ។ ទេវតាអរសល់ អរអស់កង្វល់ ពីផ្លូងទ័យា ដោយបានក្រេបរស ឆ្ពោះពីធម្មា នាំឲ្យលាភា ទេវតា ល្អូតលាស់ ។ កាលព្រះពុទ្ធចៅ ព្រះអង្គគង់នៅ ប្រោសសត្វទាំង អស់ ព្រះអង្គទ្រង់ញាណ ឥតមានបន្ទោះ នឹកហើយស្រណោះ

www.budinst.gov.kh www.elibraryofcambodia.org

អាទេព្វោះអាស័យ ។ ព្រះអង្គសំដែង ធម៌ច្រើនដាក់ស្តែង ច្រើនជាងដលស័យ ពីថ្ងៃទៀបយប់ ផុតឈប់ឈរនៃ សត្វសែនអសំខេយ្យ ក្ស័យបាននិព្វាន ។ តរូវនេះឯង យើងសឹងចម្បែង ស្វែងស្វាក់ស្រែកឃ្លាន ចង់ស្តាប់ព្រះធម៌ វិន័យទូន្មាន ដើម្បីនឹងប្រៀន បង្រៀនចិន្តា ។ បុគ្គលណាមួយ បេះអារម្មណ៍ព្រួយ ដួយគិតទេវតា វេលាធ្វើបុណ្យ និមន្តសង្ឃទេសនា បែងចែកផលា ទេវតាអរពិក ។ មិនបាច់ធ្វើរាន រុបធូបភ្ញៀន ជត្រក្ទស់ពាសដិត នាំតែពីបាក តោកយ៉ាកពួកមិត្រ នាំញាតិឆ្ងាយជិត ធុញទ្រាន់ដោយសារ ។ នៃចៅសេកអើយ បាសួរអញឆ្លើយ ឆ្លងពីរប្រស្នា ល្មមពេលវេលា យូរយារហើយណា អញសូមសួរបា ឯងបានម្តងវិញ ។ នៃសេកសោមសត្វ ហឫទ័យប្រមាត់ ខ្លួនអញទោម្នេញ ទោមនស្សអស់កល់ កំហល់ច្រើនមិញ កម្របានដេញ ដោលសួរអ្នកណា ។ ឲ្យបានដឹងយល់ សោះកើតអំពល់ ទល់ទុក្ខទៀតរ៉ា ចូរបាសំដែង ថ្លែងតាមពុទ្ធដីកា ឲ្យបានជ្រះថ្លាចិន្តាអញម្តង ។ លាក់បាំងថ្វីសេក អញសែនវិវេក ពុំស្រាកម្លួហ្មង មិនដឹងជាអ្វី បានជាមនុស្សផង ខ្លះស្លាប់វិលផ្គង រងធ្លាក់នរក ។ ខ្លះមកស្ថានសួគ៌ រាប់ច្រើនសាត្រូ កំសាន្តសោយសុខសប្បាយហួសខ្នាត ជាអាទ៍ឥតទុក្ខ ពុំធ្លូបនរក អបាយមុខនៃ ។

www.budinst.gov.kh www.elibraryofcambodia.org

សោកសោមប្រាជ្ញា បានស្តាប់ប្រស្នា ទេវតារំពៃ រំពឹងរឹងគិត ដោយចិត្តឈ្លាសវៃ ប្រឹងទំលកលៃ វៃរាយរៀបរាប់ ។ គិតឃើញ ស្រេចស្រាប់ សោកសោមចំណាប់ ហើរទំព្រឹក្សា ទើបមានសំដី ផ្អែមល្ហែមវាចា ផ្តោះកាន់ទេវតា គ្មានរអាក្រែង ។ បពិត្រទេវ៉ា ដ៏មានឫទ្ធា តេជោខែងរែង ចូរលោកចាំស្តាប់ សារស័ព្ទថ្វាថ្លែង ខ្ញុំនឹងបាយបែង តែងតាមរៀបរាប់ ។ បុគ្គលណាមួយ គ្មានចិត្ត គិតព្រួយ ជួយលើកសាសនា ព្រះបរមបមភព លុបលើលោកា មិនរៀនធម៌អាថ៌ គាថាវិន័យ ។ បន្ទន់ចិត្តតាម ចោរកិលេស-កាម តណ្ហាទីទៃ ពុំមានរន្ធត់ ចំហុតភិតភ័យ អបាយមុខនៃ ប្រាជ្ញាសប្បាយ ។ ចង់បានសម្បត្តិ សម្បូណ៌ច្រើនក្តាត់ មាស ប្រាក់លុយបាយ តាំងគ្រាប់លេលា ធ្វើឲ្យអន្តរាយ ជីវិតទាំង ឡាយ សព្វសត្វតូចធំ ។ ដើរបាញ់ដើរបោះ ដើរទាក់ស្ទូចអស់ សត្វក្នុងទ្រនំ ក្នុងរូងសម្បុក រិតក្តអ្លូលងំ សត្វខ្លះទួញយំ រលឹក គូរា ។ ដូចជាសត្វអក បើមនុស្សឡើងយក លាក់លួចកូនគ្នា មេនឹងសង្រេង ក្រសើពណ៌នា ហើរផ្ទោះម៉្ទា កាន់អាកាសនាយ ។ ឆ្ងាយហើយខ្ពស់សល់ ដោយចិត្តតប់ប្រមល់ ខ្វល់ពុំរីករាយ អក ប្រឹងបិទស្លាប ដាបជិតរឹតកាយ ទម្លាក់រំលាយ កាយស្លាប់ ដោយដី ។ ឱះឱពុំទ្វោ ខ្ញុំទោមនស្សមនោ មនុស្សចោរតិរ្ឈ៍

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តកាចសាហាវ មុតដូចដាវផ- ស្សូវរាជធិបតី បម្រើពណ្ណរាយ ។ ពុំមានមេត្តា អាសូរករុណា ចិត្តឆោតមើលងាយ ពុំស្គាល់បាប បុណ្យ ទោសគុណរាយនាយ ដើរតែរំលាយ រំលោងជីវ៉ា ។ ជីវិតសត្វផង ពុំបានកន្លង រំលងថ្ងៃណា មានពួកមនុស្សខ្លះ ឥត ភ្ញាសម្បស្សា មើលងាយពុទ្ធដីកា សម្មាសម្ពុទ្ធ ។ បង្គាប់វចនៈ ពោលតាមចិត្តស្អុត អំពើពាលពុត ថាអស់សត្វផង បើយើងធ្វើ គុត បំផ្លាញឲ្យផុត ដីពដន្ទដីវី ។ ឥតមានបាបទេ ដោយព្រះពុទ្ធ គ្មោះ ហាមតែអំពី ត្រីព្រាញ់អណ្តែង ក្តាមសាមទុកទី បឹងបួព- សុធី សម្លាប់ទោសមាន ។ មានជនជាតិខ្លះ កាន់យេស៊ូសាស្ត្រ សាស្តាប្រធាន ប្រាប់ត្រួតលើ សារពើទូន្មាន បង្ហាត់បង្រៀន តំរាក្រមច្បាប់ ។ គេថាសត្វផង កើតមកត្រូវរង ឲ្យមនុស្សសម្លាប់ ដូចជាដើមឈើ ត្រូវតែមនុស្សកាប់ មនុស្សត្រូវចងចាប់ សត្វធ្វើ អាហារ ។ ធ្វើជាចំណី បរិភោគប្រក្រតី ដប់សៀងជីវ៉ា បើពុំ ស៊ីសាច់ កម្លាំងពុំក្លា អាប់ឱនប្រាជ្ញា ជីវ៉ារីងរៃ ។ ឯពួកបាម ផ្កា អាវ៉ាប់ភាភ ក្លួតខែកទីទៃ កាន់ព្រះអាឡ្លា ឥស្សរាធិបតី ប្រ- កបញាណញៀយ្យ ឆ្លៀវឆ្លាសវិជ្ជា ។ អាឡ្លាបានចាត់ អង្គព្រះមហា- ម៉ែទ តំណាងអង្គា មកឲ្យទេសនា ប្រោសសត្វគ្រប់គ្នា នៅលើ ពសុធា នាលោកយើងរាយ ។ ជាទ្រង់មេត្តា ឲ្យពួកមនុស្ស

www.budinst.gov.kh www.elibraryofcambodia.org

រៀងរាល់រូបកាយ សម្លាប់តិរច្ឆាន ប៉ុន្មានទាំងឡាយ ស៊ីលេងសប្បាយ តែផ្សាយមេត្តា ។ គឺថាមុនកាប់ ចាក់កសម្លាប់ សម្លេះសិនណា ឲ្យធម៌សត្វនោះ ផ្ដោះកាន់សុខា គឺធកាមា ស្ពតាំនាយនៃ ។ បើធ្វើបែបនេះ សត្វនឹងរបេះ ពីភេគពីភ័យ អំពីតិរច្ឆានជាតិពុំប្រពៃ ទៅស្ពតាំល័យ និតជិតអាឡា ។ មួយទៀតសត្វត្រីអាឡាធិបតី សំដែងស្រេចណា ដោយនូវអារុធ មុតគីវ័នថ្វាស្រកីមជ្ឈា គឺស្នាមព្រះវ័ន ។ ពួកបរិស័ទផង បើចោមស្ងួចចងចាប់ត្រីត្រូវការ មិនបាច់ឲ្យធម៌ បវរជាក់ស្បាន់ អាឡាប្រសាន់ព្រះទានធម៌ហើយ ។ ថ្លែងឯពួកចិន ពោលពាក្យកាច់កិន ព្រះព្រហ្មត្រាណត្រើយ ថាម្ចាស់ព្នាយើង កុំទំនើងឡើយ កុំនៅកន្តើយត្រូវគិតជ្លេះ ។ បើមនុស្សឯណា គ្មានជាប់ទោសា យើងកុំប្រហែស បើយើងសម្លាប់ យើងធាប់របេះ ធ្លាក់នរកជេះ ភ្លើងឆេះវេទនា ។ បើមនុស្សណាវិញ អាក្រក់ទោសម្ដេញ ពេញពាសវេភា បើយើងសម្លាប់ ពិតពុំមានពៀរ នាំកើតលាភា ឲ្យយើងពិតជាក់ ។ រីឯតិរច្ឆាន ព្រះព្រហ្មអវតារ បង្កើតអន័ត្បអនេកពន្លក សន្ធកហ៊ុកហ៊ាក់ សត្វណាមនុស្សស្ម័គ្រ ដាក់ជាចំណី ។ សម្លាប់ទៅហើយ គ្មានទោសអ្វីឡើយ មិនគួរគប្បីអាណាគតអនាថ ប្រមាថិគ្មានអ្វី នេះគឺសំដី មនុស្សាពាហោ ។

www.budinst.gov.kh www.elibraryofcambodia.org

បើសត្វឯណា ពុំដាអាហារ មិនត្រូវចំយោរ យៅកាប់សម្លាប់ បាប
ក្រាស់ជ្រៅជ្រៅ នរកជ្រងៅ ដោរសុទ្ធខ្ទុះឈាម ។ ឱលោកទេវតា
ចូរពិចារណា អស់ពាក្យរីមរាម ពាក្យប្រទូសរ៉ាយ ប្រកាន់ទំនៀម
ទម្លាប់ប្បងរៀម ដេដ្ឋាជូនតា ។ មិនគិតប្រណី អំណាត់ខន្តី
អាស្សូរដីវ៉ា ដីវ័នតិរច្ឆាន ឲ្យបានសុខា គិតតែធ្វើការ លាមកអា-
ក្រក់ក្រៃ ។ បុគ្គលឯណា គ្មានសីលបាណា ធ្វើសត្វឲ្យក្ស័យ
ដោយប្រើគេឯង ឬធ្វើដោយដៃ មនុស្សនោះបង្រៃ ក្រៃបើ
គណនា ។ ដល់ខ្ជួនស្លាប់ទៅ ធ្លាក់នរកជ្រៅ រងកម្មវេរា ភារៈ
យូរលន់ ទុរន់ក្រាំក្រា ខានឮពុទ្ធា ទេសនាទូន្មាន ។ ខ្ញុំសូម
សរសើរ ដំណាលដំណើរ ព្រះអនាវរញ្ញាណ ព្រះអង្គអាស្សូរ សត្វ
ទុទៅគ្មាន ស្ពៀងឃ្លោងវៀវរាង បំហៀងតូចណា ។ ប្រដៅ
សព្វសត្វ កុំឲ្យបំបាត់ កំចាត់ជីវ៉ា ត្រូវតែកោតខ្លាច ជីវិតរូបា
រាល់រូបកាយា សត្វក្តីមនុស្សក្តី ។ អស់ពួកបណ្ឌិត លោកតែង
ប្រព្រឹត្ត ធ្វើការគប្បី ពុំឲ្យសៅហ្មង រំលងខន្តី ចិត្តស្ងួនមេត្រី
ប្រណីមេត្តា ។ រហូតដល់ស្លាប់ លោកបានដាបាប់ កំណើត
អស្ចារ្យ នាទេវស្ថាន អវតារឱទ្យារ- រិកកបបេស្តា សុខាភិរម្យ ។
ប្រការ ២ ទៀត មានជនច្រើនជាតិ ឃាតខ្មីពិតពុំ ខិតខំរកស៊ី
តាមទំនិតម មិនបេះនិយម តាមកិច្ចក្រាដ្ឋប្រាយ ។ ចែងតែ

www.budinst.gov.kh www.elibraryofcambodia.org

ស្រណុក ហើយដើរតគ្រុក ធ្វើឲ្យអន្តរាយ រកលួចផក់ប្លន់ គំបន់ទាំងឡាយ នាដននិតធ្លាយ ក្រហាយខ្លោចផ្សា ។ ខ្លះតាំងខ្លួនជា ស្តេចចោរមាយា នាព្រៃព្រឹក្សា ប្រជុំពួកខូច ទិលផ្ទួចអាត្មា ប្រកាសខ្លួនថា ជាស្តេចនរបតី ។ ធ្វើជាមេក្លោង ទៅណាសព្វេភាង ពួកចោរអប្រីយ៍ រកលុយលុកប្លន់ រៀងរាល់រាត្រី បានទ្រព្យហើយខ្មី ដេកផឹកស៊ីលេង ។ មានក្មេងចាស់ខ្លះ ពុំមានអៀនខ្មាស ថ្លើមបះធំធេង សំរុកដោយផ្សារ នេត្រាប្រឹងឈ្លេង ក្រែងដនវង្វេង ភ្លេចភ្លាំងស្មារតី ។ ដាក់ចោលអីវ៉ាន់ ទិញហើយពុំកាន់ កប់ទុកក្នុងល្អី ចោរឃើញកាលណា ប្រឹងឆ្លេឆ្លាខ្មី ដើរផល់ចំណី ផក់យករត់ប្ញាត់ ។ គេដេញចាប់ឈ្លូ ចាប់បានមុខដូរ ដូចមុខស្វាសត្វ គេផាក់វាយធំ ដំណាំដាំក្តាត់ ចោរអើយម្តេចគាត់ មារយាទបោកលន់ ។ បពិត្រទេវតា បំណែកករាជការគ្រប់គ្រងមហាជន ទំនិញទាំងឡាយ គេឲ្យបង់ពន្ធ ជូនស្រាលប្អូនធូន់ ទន់តាមតម្លៃ ។ ប៉ុន្តែមានមនុស្ស ពិតពុំខ្លាចខុស គំនិតឃ្លោងប្រែ ខ្លួនខ្ញុំនេះឯង គាប់ប្អូនមួយថ្ងៃ បានឃើញស្មាដៃ ចៅពាលមួយណា ។ វត្តដែលខ្ញុំនៅ ថ្ងៃមួយនោះត្រូវ ឧបា-សកសិកា ដង្ហែកឋិន ពេលចេញវស្សា មានទូករោត្រា ដោតទង់ដេរដាស ។ ប្រុសស្រីខ្លួលខ្មៅ ដីឆ្ងួនពចៅ តាយាយចាស់ៗ

www.budinst.gov.kh www.elibraryofcambodia.org

ស្លៀកសពាក់ស ទេសឯកយ៉ាងក្រាស់ បានម្លូប់ច្រើនជាស ពាស លើភេត្រា ។ កំទេព្រោះក្រមុំ ដោះណែនក្រពុំ តែងតួអាត្មា ស្លៀក ពាក់ហូលព្រៃ ព្រាំគាតក្រម៉ា ស៊ុផ្លូចកញ្ញា ទេវតានាយ ។ មែន មានពាណិជ លក់ថ្នាំចង់គេច ពន្ធឲ្យបានងាយ ក៏គុបតែងទូក បានល្អពណ៌ភាយ ចងសុទ្ធរំភាយ ភាយពណ៌ភ្លឺថ្លា ។ ចែវមុខផ្ទះ គយ ទូកលឿនរពិយ ពាណិជប្រាប់ថា ឲ្យពួកអ្នកចែវ ស្រែក ច្រៀងសកភាទី កុំឲ្យរាជការ សង្ស័យដល់ខ្លួន ។ ថ្លែងឯមេគយ ឃើញទូករាប់រយ ពិតពុំគុំគួន ថាគេធ្វើបុណ្យ ល្អលន់តាមក្បួន ពុំគួររុកកួន ដែកដេរទៀយណា ។ ចៅពាណិជពាល ចែវទូក ឆ្លងភាល ទន្លេផលសា ថ្នាំក៏រួចពន្ធ ពុំស្គុនខាតការ បំភាន់រាជការ ដោយស្នាដៃភា ។ ប្រាជ្ញពុំស្មើពុត ធម្មជាតិគ្រឿងមុត ពុំស្មើទ័យ្យា បិត្តចោរសាហាវ ដូចដាវអាវុធា ដូចខ្ញុំពណ៌នា រឿងនាយពា-ណិជ ។ ជនជាតិបណ្ឌិត លោកតែងចេះគិត យល់សព្វសេច ក្តេច មិនដែលបំបាត់ លួចលាក់ស្តាយរេច លោកពិតពុំលិច លង់ទៅអបាយ ។ នរូជនពាល តណ្ហាពេលភាល ផ្ទៀលទ្រូង ក្រហាយ ដើរលួចបំបាត់ ស្លាប់ទៅធ្លាក់កាយ នៅនាអបាយ ភពភូមិរងក្តៅ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រការ ៣ ទៀត ខ្ញុំសែនបង្អៀត បង្អួលភ្លេងសៅ ឃើញ ពួកពាលា ចិត្តអាក្រក់ខ្មៅ ដើរលួចកូនចៅ សាច់ឆៅព្រៀង ណាន ។ លួចប្រពន្ធគេ យកធ្វើជាមេ ផ្ទះដោយបំពាន មិន គិតរអែង ខ្លាចក្រែងបាបមាន ជាទីប្រមាន ប្រឆ្លូនអវិចី ។ មានកំឡោះពាល មិនដឹងធ្ងន់ស្រាល កាចអន្ធពាលស្ពាក់ ស្កាត់ដើរចង់ស្រី ដូនកាលកើតក្តី អាស្រូវបាភយ ។ បរាវិនាស អាក្រក់ពេញពាស ស្អុយឈ្មោះអំសាយ ដូនគេលួចកាប់ សាប់ អង្គរាងកាយ ខូចខ្លួនអន្តរាយ ចោលមាតាបិតា ។ បពិត្រទេវេ- ជនក្រាស់រាគោ កិលេសកាមា ពុំដែលចម្រើន កើតកើនផលា មាន តែអសារ ខុសខាតចង្រៃ ។ កើតព្យាធិរោគា ខូចខ្លួនអាត្មា រាល់គ្នាទីទៃ ព្រោះមិនប្រព្រឹត្ត តាមក្រិត្យវិន័យ ពុំចេះលកលៃ ភ័យខ្លាចបាបណា ។ ឯព្រះមោហម័ទ អំណាចច្រើនក្តាត់ គុំ- ណាងអាឡ្លា មានអគ្គមហេសី ស្រីស្រស់កញ្ញា ១៥ រូបា សាវិតារ កត់ជាក់ ។ មោហម័ទចមពង្ស ពូជអាឡ្លាវង្ស ត្រដុងអគ័ត្ប បានហាមប្រាមដល់ បណ្តាអស់អ្នក មានចិត្តភក់ទាក់ កាន់ សាសន៍ព្រះអង្គ ។ ជាទ្រង់អនុញ្ញាត ឱ្យមនុស្សគ្រប់ជាតិ សង្វាត ត្រឹមត្រង់ ស្វែងយកភរិយា តាមដោយបំណង់ បានតែ ៤ អង្គ ម្នាក់ៗ ទេណា ។ ប្រុសពេញមានភ័ព្វ ជាទីគំនាប់ ជាប៉ី

www.budinst.gov.kh www.elibraryofcambodia.org

ដោកតណ្ហា បានអំណាចល្អ ពីព្រះអាឡា ប្រុសមួយអង្គា ប្រពន្ធ ៤នាក់ ។ ឯអង្គព្រះពុទ្ធ ព្រះទ័យបរិសុទ្ធ បំផុតឯកអគ្គ ទ្រង់ពុំត្រេកអរ នឹងភាគអប្បល័ក្ខណ៍ ដូចចិត្តពួកអ្នក សាស្តាដទៃ ។ ព្រះអង្គតិះដៀល ទ្រង់ពុំនៅលៀល ជិតភាគចង្រៃ ទ្រង់បានកំចាត់ បំបាត់ដោយញាណ្យ- ធម៌ល្អប្រពៃ ព្រះទ័យជ្រះថ្លា ។ បពិត្រទេវៅ ប្រសើរអគ្គោ បុគ្គលឯណា មានចិត្តស្អប់ខ្ពើម ស្អើមភាគតណ្ហា កាលក្ស័យជន្មា កើតទៀតសុខពិត ។ បុគ្គលណាមិញ មិនប្រឹងបំពេញ កុសលសុចរិត រង់រុយងប់ងល់ លើ អេងើងងឹត ភាគៈនោះរឹត ឲ្យធ្លាក់អបាយ ។

ប្រការ ៤ វិញ មានមនុស្សពាសពេញ នៅនាស្រុកអាយ ពោលពាក្យបញ្ឆោត បំពោតសុសសាយ នាំក្តីអន្តរាយ ជនឆ្ងាយជិតផង ។ ខ្លះបញ្ឆោតលេង កិរិយាដូចក្មេង តាមដោយបំណង ឲ្យគេពិបាក តក់ស្លុតរោកកន្លង នាំកើតសៅហ្មង រងទុក្ខដោយសារ ។ ដោយខ្លួនចង់លេង ឲ្យគេវង្វេង វិលវល់ចិត្តា ស្មារតីឡប់ភាំង ពាំងអស់តរិយា- បថដែលល្អថ្លា ពុំក្លាក្លៀវបាន ។ មានខ្លះបញ្ឆោត ពោលពាក្យល្អសោត ល្ហួងលោមសន្តាន ឲ្យពេញសណ្តាប់ ស្តាប់ជឿជាក់ក្តាន ពួកជនប៉ុន្មាន ស្មានថាមនុស្សល្អ ។ គេជឿចិត្តដាក់ ខ្លួនអរអនឹគ្ឃ ភក់ទាក់ស្មោះសរ គិតធ្វើមាយា

www.budinst.gov.kh www.elibraryofcambodia.org

ពាលាគិតផ លោកយកអង្ករ មាសប្រាក់ស្បៀហ្វូល ។ ខ្លះបេះ
បញ្ឆោត ពោលពាក្យចាក់ដោត បញ្ចេញបញ្ចូល ឲ្យគេវិនាស
សម្បត្តិសម្បូណ៌ វង្សាត្រកូល ត្រកាលព្រៀងលាន ។ បុគ្គលឯ
ណា ពោលពាក្យមុសា បំផ្លើសបំពាន ដល់ស្លាប់ទៅវិញ ទោ
ម្ទេញសោកសាន ក្នុងនរកមាន បុព្វោខ្ទះទាប់ ។ ជនជាតិបណ្ឌិត
លោកប្រកបចិត្ត ម៉ាំងទាំងចំណាប់ ច្រើនកាន់សច្ចំ តាំងជាប់ចង
ចាប់ ទើបបានក្រឡាប់ ស្លាប់កើតត្បូតាំ ។

ប្រការ ៥ ទៀត ខ្ញុំសែនបង្អៀត តៀ្យតក្នុងហទ័យា ដ្បិតឃើញ
ពួកមនុស្ស រឹងរូសពាលា កាចកោងមុះហិមា គណនាពុំបាន ។
ដើរផឹកសុរា តាមដោយទំផ្សារ ស្រវឹងភ្លេចប្រាណ ប្តូនកាលដួល
ដេក ដោយមាត់ស្កាន ពុំដឹងដើមដាន ភ្លឹកបាត់ស្មារតី ។ អស់
មនុស្សឈ្លូធរ គឹកកងអ៊ូអរ ទាំងប្រុសទាំងស្រី នាំគ្នារត់មក រក
មើលដោយដី សុរាអប្រីយ៍ កើតក្តីខ្មាសគេ ។ ពួកអ្នកប្រមឹក
ប្តូនកាលស៊ីផឹក រួចហើយស្តីដេរ បំអាស់បំអួង វាយមាយពុំត្រេ
ដេរដល់បាមេ គេតតសំបៃ ។ ប្តូនកាលសន្តាន ទប់ចិត្តពុំបាន គេ
ប្រាណផាក់វៃ ប្តូនកាលគេប្តឹង ដឹងដល់ក្បត្រថ្ងៃ ស្តេចលោកពុំន័យ
ព្ទែលក់តាមការ ។ មានអ្នកផឹកខ្លះ ទាតបង់ក្តេរខ្មាស មាតាបិតា
បើស្រវឹងហើយ សើយលាត់កាយា ននៀលផ្កាប់ផ្ងារ ផ្កាដៃផ្កាជើង។

www.budinst.gov.kh www.elibraryofcambodia.org

សុរាក្តៅសល់ ក្តៅទាំងសកល ផ្តល់ឡើងដូចភ្លើង ធ្លួលដួងហឫ-ទ័យ ស្មើរនឹងរលើង រលួយពើតពើង ប្រាជ្ញារលីរលល់ ។ អវិជ្ជាចូលបាំង ធ្វើចិត្តក្លៀវខ្លាំង ភាំងគ្មានទប់ទល់ ប្រមាទកើតឡើងធ្មើងចិត្តងប់ងល់ គ្មានគិតរវល់ ពីកុសល ។ ជំពូកជនខ្លះ មានកម្មដោកក្រាស់ ផាសផាប់រូបា ប្រឹងដក់អាភៀន ភៀនដក់កញ្ឆាជាបែកប្រាជ្ញា គិតការកើតងាយ ។ បពិត្រទេវា រីមនុស្សពាលោគំនិតភាយមាយ យកស្រាអាភៀន ធ្វើជាសម្លាយ ប្រើជាបាឡាយរលាយដាប់ក្អាត់ ។ មនុស្សផឹកសុរា ធ្វើឲ្យប្រាជ្ញា អាប់ឱនរសាត់រសល់អស់ទៅ កើតរោគឈឺថ្កាត់ នាំឲ្យខ្វាយខ្វាត់ ភ្លាត់យសសក្តា ។ មិនស្គាល់ទោសគុណ ជេរវាយប្រពន្ធ បុត្រីបុត្រា ប្រមាទព្រះសង្ឃ អង្គអរហន្តា បំផ្លាញសាសនា វិនាសអប្រីយ៍ ។ មនុស្សដក់អាភៀន កម្រស្រែកឃ្លាន ធ្វើការលោកិយ ដក់ពីព្រលប់ដល់យប់រាត្រី កើតបេះសំដី ព្រោកប្រាជ្ញវែងឆ្ងាយ ។ ទាំងត្រូវទាំងខុស ទាំងភាន់ជ្រលួស រាប់មួយពាន់ប្លាយ ពុំគិតបុណ្យបាបស្អុយឆ្អាបទាំងឡាយ គិតតែសប្បាយ ណាយការកុសល ។ ទ្វីបអាមេរិកាំង រាជការឃាត់ខាំង ហាមប្រាមប្រាប់ដល់ បណ្តាមហាជន ខ្ញុំទាំងសកល មិនឲ្យខ្វាយខ្វល់ អាភៀនសុរា ។ ឥឡូវស្រុកចិន កាន់តែបេះប៉ុន មានច្បាប់រាជការ ហាមផ្តាច់មិនឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

បណ្ដោយមនុស្សា ដក់អាភៀនកញ្ឆា ជាការពុំគាប់ ។ បុគ្គល
ឯណា ក្រេបរសសុរា លុះផឹកខ្លួនងាប់ ជាប់ទោសនរក កលិយុគ
បំប្រប់ មាត់សឹងភ្លើងឆាប់ ញាំញាប់វេទនា ។ ជនជាតិប្រាជ្ញ
ប្រាយ លោកបេះដោះកាយ ឆ្ងាយចាកភ័យា លោកមិនបេះផឹក
នូវទឹកសុរា មិនមានពាធា ធម្មាទីទៃ ។ ដល់រលត់ខន្ធ
លោកត្រាច់ចូលកាន់ ឯស្ងួតាល័យ ឆ្ងាយពីទុក្ខសោក វិមោក្ខរោគ
ភ័យេ កបឫក្សជោគជ័យ បច្ច័យនិព្វាន ។ បពិត្រទេវា ខ្ញុំថ្លែង
ពណ៌នា ហេតុដែលប្រធាន ធ្វើឱ្យសត្វផង រងទុក្ខសោកស៊ាន
តាមពត៌មាន ខ្ញុំបានសិក្សា ។ ខ្ញុំបានសំដែង អធិប្បាយបារ
ពែង ថ្លែងហេតុកិច្ចការ ដែលធ្វើសត្វលោក ជោគកើតសុខា
បានធកាមា ស្ងួតប្រាំមួយជាន់ ។ ពុំបានសព្វគ្រប់ តែខ្ញុំសូមឈប់
ដោយគិតរិះគ្នាន់ ចង់ធ្វើដំណើរ ហើរឱ្យរួសរាន់ ឱ្យបានទៀបទាន់
ល្ងាចត្រជាក់ណា ។ ទេវាបានស្ដាប់ សំដីសារសព្ទ សេកសោម
បក្ខា ហឫទ័យរីករាយ ផ្សាយសាធុការ ឱ្យពរបក្សា អនេកបរិយាយ ។
ជាតែសេកសោម ប្រកបដោយឆោម លោមពណ៌ត្រសាយ
យើងសូមឱ្យពរ បវរជើតឆាយ ចូរបានឧកាយ ទទួលឆាប់ភ៉ា ។
យើងសូមពរពី ឥន្ទ្រាកោសិយ ស្ដេចត្រួតទេវតា សូមជួយព្យាបាល
ត្រអាលរក្សា ឱ្យបានសុខា តាមដោយផ្លូវឆ្ងាយ ។ យើងសូមពរពី

www.budinst.gov.kh www.elibraryofcambodia.org

ព្រះឥស្សរឫទ្ធិ គ្រូគសត្វទាំងឡាយ សូមឲ្យជួយថៅ ឆោមឆ្មៅផេត ឆាយ កុំឲ្យអន្តរាយ រូបកាយថៅឡើយ ។ អាយុវណ្ណ៍ សុខំពលំ ទៅចុះជាអើយ សព្វទុក្ខសព្វសោក សព្វរោគឲ្យស្បើយ ឲ្យបានដល់ ត្រើយ និព្វានឆាយណា ។ បក្សាសេកសត្វ ត្រេកអរពេកក្តាត់ ទើបទទួនសិរសា ក្រាបថ្វាយបង្គំ ប្រណម្យទេវតា លុតលាយាត្រា ចេញចរឆាប់វៃ ។ តាមដោយអាកាស ពពកធំក្រាស់ ផ្សែងអាប់ព្រឹក្ស ព្រៃ មេឃមីរងងឹត សេកគិតរំពៃ ហិចហើរឥតភ័យ ពីការនឿយ ណាយ ។ រឿងសេកនេះណា ខ្ញុំឈប់ចរចា ពុំទាន់អធិប្បាយ ខ្ញុំសូម ព្រោរព្វ រឿងឥសីសាយ យកមកបរិយាយ រាយតាមបែបផែន ។ ព្ធដំកាលនោះ តាបសមួយឈ្មោះ តាឧរាំណែន លោកចេញចាក ស្រុក តីរភពទីដែន លោកមកបន្លែន បន្ថុកុសល ។ តាបស នោះណា លោកគិតសាសនា ចិន្តាស្រងល់ ស្រងូតស្រងាត់ រសាប់រសល់ ព្រះទ័យសួតវល់ ពីព្រះធម្មា ។ កាលលោកទៅ បួស បានទទួលផ្នួស អំពីឧបជ្ឈាយ៍ លោកសឹងទោមនស្ស ព្រួយអស់អង្គា ឃើញសង្ឃនានា ពុំរៀនវិន័យ ។ ស្រយុត ស្រយាល អផ្សុកកលផាល ព្រួចព្រំព្រះទ័យ ដោយឃើញឧបជ្ឈាយ៍ ពិតពុំមានវៃ កូនសិស្សទីទៃ ធ្វើតាមប្រាថ្នា ។ ខ្លះលួចឆាន់បាយ ល្ងាចសោះក្រហាយ ក្រហល់កាយា កាន់លុយកាក់កាស តាស

www.budinst.gov.kh www.elibraryofcambodia.org

ពេញហត្ថា លួចផាន់សុរា ភ្លៀវក្លាទាត់សី ។ ខ្លះបិញ្ជឹមគោ ក្របី ពាសពោរ សេះលាដំរី ថែមមានរទេះ ទីតាំងហត្ថី បើឃើញស្រីៗ ញញឹមប្រិមភ័ក្ត្រ ។ ខ្លះមានទូកង ទះដៃបន្ទរ អុំភ្នាល់ដាក់ប្រាក់ ខ្លះមានរបាំ រាំប្រសើរស័ក្តិ ខ្លះបេះគូរឆ្លាក់ ចាក់ក្បាច់ស៊ុឈ្នួល ។ ភិក្ខុឧភណែន- ឃើញហើយសល់សែន បិន្តាព្រំអួល អន់អាក់ពេក ក្រៃ ព្រះទ័យរំជួល រឹតរឹងតែក្តួល ក្តៅរាល់វេលា ។ លោកក្រិះ គិតថា ឧត្រូអាត្មា ជាតិជាឧបជ្ឈាយ៍ ម្តេចលោកល្ងង់ខ្លៅ សល់ សៅមុះហិមា ពុំមានពណ៌នា ប្រដៅសិស្សផង ។ ឧឧបជ្ឈាយ៍ អញ គិតទៅគួរភ្ញាញ់ ដូចទាកន្លង កើតកូនរួចស្រេច ទាត្រាច់ បោលពង ពុំមានគ្រប់គ្រង ភ្ញាស់ថែរក្សា ។ មិនដូចសត្វមាន់ ពងហើយរួសរាន់ ក្រាបក្រាលអាត្មា នៅលើសំបុក ត្រសុកកាយា ឲ្យកូនអាត្មា ញាស់រស់ជីវិត ។ ភិក្ខុនោះឯង លោកសឹងចំបែង តែងអារម្មណ៍គិត ដល់បានឱកាស ជ្រះល្អដាក់ពិត លោកនិមន្ត មិត រត់បោលវត្តវៃ ។ ចូលក្នុងគិរី មានរូងជាទី ធ្វើអាស្រមនៃ បង្ក្រមភាវនា ប្រឹងរឹងរំពៃ ចម្រើនញាណញៃយ្យ មមៃឯកឯង ។ លោកធ្វើកសិណ ដែលលោកធ្លាប់ប៉ិន ប្រសប់ខែងវែង អគ្រាត្រ កាលណា យាត្រាស្ទះស្ទែង រកទីកន្លែង ស្ងាត់ពិចារណា ។ លោកយកដីទឹក អារម្មណ៍រិះនឹក ដល់រាងរូបា ដល់ស្លាប់ស្អុំឲ្យឈឹង

www.budinst.gov.kh www.elibraryofcambodia.org

ទ្រមឹងឯកា រាងរូបអាត្មា ទៅជាធរណី ។ ឈាមដ៏រទាំងឡាយ
សឹងបង្វែរក្លាយ រាយលើប្រថពី ទៅជាគង្គា នៅនភាលិយ៍(១) នេះបំ
ជាទី សង្វេគពេកណាស់ ។ លោកយកភ្លើងខ្យល់ តាំងទុកតំកល់
គិតតាមពុទ្ធសាសន៍ ធ្វើជាកសិណ សង្កិនឲ្យច្បាស់ លុះអរុណរះ
ទើបវិលគូហា ។ តាបសឥសី លោកកាន់ខន្តី ចម្រើនមេត្តា អធ្យាគ
ទុក្ខសត្វ និងមនុស្សនានា បាលីធម្មា លោកបានរៀនស្ទាត់ ។

នេះបទព្រហ្មគីតគាប់ ខ្ញុំរៀបរាប់តាមបាទបទ ដំណើរសោក
សោមសត្វ ហិចហើរកាត់លើព្រឹក្សព្រៃ ។ ខ្លួនប្រាណទន់ល្វន់ល្វើយ
បក្សាឆ្មៀយហាត់សន្ធៃ សន្ធឹកស្ងួតរីងរៃ ស្ទើរតែក្ស័យប្រល័យជន្ម ។
បក្សាប្រឹងហិចហើរ កបដំណើរល្អុទន់ភ្លន់ ប្រឹងខំមាត់អត់ធន់ រកអ្នក
បុណ្យឆ្លាតវិជ្ជា ។ ហើរឆ្ពោះទាំងថ្ងៃយប់ ពុំបានឈប់មួយទិវា ទិតទំ
ព្រាចលីលា ក្ដៅរងាពុំមានគិត ។ ដល់ទៀបដងគិរី ដែលឥសី
លោកនៅនិត ដួនមេឃខ្មៅងងឹត ខ្យល់បាំងបិទព្រះសូរ្យឆាយ ។
សត្វសោកវែងពិភាល់ គិតនឹកឆ្ងល់ហេតុឧបាយ ឱះឱអញអន្តរាយ
កាយទេដឹងថ្ងៃនេះណា ។ ទើបសត្វពង្សបណ្ឌិត ហើរទំជិតថ្មសិ-
ណា ឆ្លូងនេត្រប្រឹងធ្វេឆ្លា មើលព្រឹក្សាឈើតាប់តាន់ ។ គាប់ប្អូន
បែតឲ្យផាក់ នាំកន្ត្រាក់នេត្ររន្ធាន់ ឲ្យសោកក្រទៀកកាន់ យល់
ជាក់ស្ប៉ាន់ទីគូហា ។ ទីស្ថានឥសីសិទ្ធ៍ ដែលប្រព្រឹត្តស្អាងធម្មា

www.budinst.gov.kh www.elibraryofcambodia.org

ឃើញហើយសោកម្នីម្នា យាត្រាចូលក្នុងរូងភ្នំ ។ ចូលជិតដល់កាល
ណា ពេលនោះមហាឥសីផ្ទុំ សោកឃើញហើយស្រែកយំ លាន់ឮធំដុំ
ស្ពានស្ពាត់ ។ សោកស្រែកពិលាបខ្ទួញ ដង្គង់ក្រួញក្រាបប្រណិប័តន៍
ថាខ្ញុំប្រឹងកាត់ យូរពេកក្តាត់ច្រើនខែណា ។ មករកអ្នកប្រាជ្ញប្រាយ
ដោះដោះស្រាយរឿងធម៌អាថ៌ ឥឡូវបានយល់តា បរសីលាល្អសោ-
ភ័ណ ។ នេះគឺបុណ្យពីព្រេង មិនវង្វេងដោយមោហន្ធ ខ្លួនខ្ញុំបានគិត
គន់ ចង់ពើបពះយល់អ្នកប្រាជ្ញ ។ កុសលផ្តល់ទាំងគ្រប់ ជួយគ្មាន
ឈប់ប្រសើរស្ងាច អស់សត្វសាហាវកាច ពុំអាចហានពារលង ។
តាបសមុនីសីលា ឮបក្សាយំរំពង ពោលពាក្យល្អបំព្រង ឥតមាន
ភ្លងបេះភេហារ ។ ទើបឥសីតើនចាក ហើយទ្រង់ងាកឈ្មៀងនេត្រា
យល់សោកយំសោកា ជិតកាយាលោកតាឆ្ងល់ ។ ទើបលោកមាន
បន្ទូល : សួរអស់មូលហេតុកិច្ចកល ថានែសោកអញឆ្ងល់ ម្តេចមក
ដល់ស្ថានអញា ។ តាំងពីអញមកនៅ ក្នុងព្រៃជ្រៅដើងបញ្ញា
មិនដែលមានអ្នកណា មកសោកាយំថ្នេះនៃ ។ សោកប្រឹងឱនសិរ-
សា គបពុទ្ធដីការំពេចវៃ បពិត្រមុនីញាណញៃយ្យ សូមអភ័យទោស
សត្វខ្ញុំ ។ ខ្ញុំពីដើមនៅវត្ត ទើបខ្វាត់ព្រាត់ចាកទ្រនំ ស្វែងរកអ្នក
